ក្រសួងអប់រំ យុវជន និង កីឡា

# ៧ ការប្រកួតសិល្បៈ

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ


នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

**វត្ថុបំណង** ៖ ចូលរួមចំណែក ឬ រៀបចំការប្រកួតសិល្បៈមួយស្តីពីពលកម្មកុមារ





**លទ្ធផលរំពឹងទុក** ៖ ជំរុញការសម្តែងសិល្បៈ និង លើកកម្ពស់ការអប់រំ និងការយល់ដឹងរបស់សហគមន៍

## ការកំណត់ពេលវេលា

បង្រៀន៣ពេលដោយមានការបង្រៀនបន្ថែម ឬការបង្រៀនសម្រាប់ការរៀបចំការងារសិល្បៈ

## ហេតុផល

ការសម្តែងសិល្បៈមានអត្ថន័យធំធេង ហើយធ្វើឱ្យទស្សនិកជនមើលឃើញកាន់តែច្បាស់នូវបញ្ហាពលកម្មកុមារ។ ប្រសិនបើអ្នកបានអនុវត្ត មេរៀនក្នុងសៀវភៅស្តីពីការបិទរូបភាពបានចប់សព្វគ្រប់(តាមការណែនាំ) ក្រុមរបស់អ្នកនឹងយល់ថា បញ្ហាពលកម្មកុមារគឺស្ទើរតែគ្មានចុះផ្សាយក្នុងប្រព័ន្ធសារព័ត៌មានទាំងអស់ ហើយសៀវភៅនេះបើកភ្នែកមនុស្សទាំងឡាយឱ្យឃើញនូវបញ្ហាពលកម្មកុមារនេះ។ វិធីធ្វើឱ្យសាធារណជនចាប់អារម្មណ៍ និងធ្វើឱ្យគេស្គាល់បញ្ហាពលកម្មកុមារផ្នែកមួយនៃដំណើរការនៃការនាំយក ជីវិតរបស់ពួកគេចំពោះចំណាប់អារម្មណ៍ជាសាធារណៈមានន័យថាធ្វើឱ្យប្រជាជនមើលឃើញនូវបញ្ហាដ៏ធំនេះនៅចំពោះមុខពួកគេ។



ការប្រកួតសិល្បៈ និងអាចធ្វើឱ្យយុវជនក្មេងៗ ចេះធ្វើរូបភាពស្តីពីពលកម្មកុមារនៅលើក្រដាស ជីតដ្ឋ រួចយកទៅដាក់តាំង ហើយបន្ទាប់មកពួកគេដាក់តាំងជាពិពណ៌សម្រាប់មើលទាំងអស់គ្នា។ នេះជាមធ្យោបាយមួយសម្រាប់ឱ្យក្រុមកុមារសម្តែងនូវគំនិតរបស់គេ តាមរយៈសិល្បៈ និងធ្វើឱ្យសហគមន៍យល់ច្បាស់នូវសាររបស់ពួកគេ តាមរយៈសម្ភារដ៏មានឥទ្ធិពលសក្តិសិទ្ធិនេះ។

សៀវភៅរូបភាពនេះធ្វើឱ្យបុគ្គលមានការអភិវឌ្ឍន៍កាន់តែខ្លាំងឡើង និងធ្វើឱ្យមានភាពស្និទ្ធស្នាលនឹងគ្នានៅក្នុងក្រុមការងារទៀតផង។ ការអនុវត្តន៍សកម្មភាពនេះ និងជួយអ្នកឱ្យចេះវាយតម្លៃពីសក្តានុពល និងចរិតលក្ខណៈរបស់យុវជនក្មេងៗដែលកំពុងធ្វើការជាមួយអ្នក។ ការអនុវត្តនេះនឹងផ្តល់នូវគុណភាពជាច្រើនដូចជាគុណភាពនៃការដឹកនាំទំនាក់ទំនង និងចំណាប់អារម្មណ៍ជាពិសេសដូចជានៅពេលដែលពួកគេត្រូវបានបញ្ជាឱ្យរៀបចំការប្រកួត ឬព្រឹត្តិការណ៍ណាមួយ តាំងពីដើមរហូតដល់ចប់។ ការសប្បាយរីករាយជាច្រើនតាមរយៈសិល្បៈអាចឈានទៅទទួលលទ្ធផលគ្រប់បែបយ៉ាងដែលគេចាប់អារម្មណ៍យ៉ាងខ្លាំង។



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

រូបភាពក្នុងសៀវភៅនេះ អាចឱ្យគេប្រើប្រាស់គ្រប់ពេលវេលាស្របទៅតាមព័ត៌មានមូលដ្ឋាន។ មេរៀនស្តីពីការប្រកួតសិល្បៈមិនត្រូវបានភ្ជាប់ទៅមេរៀនដទៃទៀតទេ ហើយអ្នកគួរប្រើមេរៀននេះនៅពេលដែលអ្នកគិតថាវាសមស្រប។ ប៉ុន្តែមេរៀននេះ អាចយកទៅប្រើជាមួយយុទ្ធនាការនៃប្រព័ន្ធសារព័ត៌មាន ដូច្នេះអ្នកអាចរៀបចំមេរៀននេះនៅពេលម៉ោងជាមួយគ្នានឹងប្រព័ន្ធសារព័ត៌មានដែលអាចដាក់ឈ្មោះថាសៀវភៅព័ត៌មាន។

## ការរៀបចំ



វិធីប្រើមេរៀននេះមានពីរយ៉ាងគឺ ៖

- ការសម្តែងសិល្បៈអាចត្រូវបានគេរៀបចំជាមួយក្រុមពាក់ព័ន្ធតែប៉ុណ្ណោះ។ នេះគឺជាជម្រើសដ៏ល្អមួយ ប្រសិនបើបរិស្ថាន និងកាលៈទេសៈ ធ្វើឱ្យការសម្តែងជូនសហគមន៍។ ឧទាហរណ៍ ដូចជាការសម្តែងសិល្បៈដើម្បីអប់រំសហគមន៍នៅតំបន់ជនបទដាច់ស្រយាលជាដើម។
- ការសម្តែងសិល្បៈគប្បីធ្វើជូនសហគមន៍ ប្រសិនបើកាលៈទេសៈអនុញ្ញាត ឧទាហរណ៍ ក្នុងសាលារៀន ស្ថាប័ន ឬ តំបន់ក្រុង។ លើសពីនេះទៀត យើងត្រូវតែរក្សាទុកក្នុងអារម្មណ៍ជានិច្ចនូវចំណុចដូចតទៅ ដើម្បីរៀបចំសម្រាប់ការអនុវត្តនៃមេរៀននេះ ៖
- ដោយគោរពតាមទម្រង់សិល្បៈដែលបានអនុម័តសម្រាប់ការប្រកួត ចូរចងចាំក្នុងអារម្មណ៍ថា ការបិទរូបភាពត្រូវបានប្រើរួចហើយក្នុងមេរៀនខាងដើម ដូច្នេះ

ហើយយើងមិនគួរប្រើវាម្តងទៀតទេប្រសិនបើអាច ។

- គ្រប់ការសម្តែងតែងតែមានប្រធានបទមួយ ហើយនិងវត្ថុបំណងមួយ ។ តើការប្រកួតនេះធ្វើឡើងសម្រាប់អ្វី? តើអ្នកចូលរួមប្រកួតសិល្បៈនឹងត្រូវបានស្នើឱ្យគូររូបភាពនៃពលកម្មកុមារឬទេ? តើការប្រកួតនេះផ្តល់សារៈប្រយោជន៍យ៉ាងដូចម្តេចដែរ? តើការបង្ហាញប្រធានបទមួយដែលនាំមកនូវក្តីសង្ឃឹមនៅពេលអនាគត គឺជាការល្អប្រសើរដែរឬទេ? តើបេក្ខជនអាចត្រូវបានគេស្នើឱ្យធ្វើផ្ទាំងរូបភាពដើម្បីផ្សព្វផ្សាយគម្រោងរបស់អ្នកដែរឬទេ? សូមផ្តល់គំនិតឱ្យបានច្បាស់លាស់ចំពោះការស្នើនេះ ។ តើផ្ទាំងរូបភាពមួយណាត្រូវឱ្យគេពិភាក្សាយ៉ាងក្បោះក្បាយនៅពេលចុងក្រោយ ។

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ក្នុងមេរៀននេះ សកម្មភាពស្នើសុំឱ្យធ្វើនោះ មិនមែនសុទ្ធតែមានបំណងចង់ឱ្យគេអនុវត្តទាំងអស់នោះទេ ។ ប៉ុន្តែប្រសិនបើអ្នករៀបចំការប្រកួតសិល្បៈថ្ងៃក្នុងមួយ ជាមួយក្រុមរបស់អ្នកដូចបានរៀបរាប់ក្នុងសកម្មភាពទី១ ហើយទទួលបានជោគជ័យនោះ អ្នកអាចត្រិះរិះពិចារណារៀបចំនូវការប្រកួតលើកទី២ ដោយអញ្ជើញអ្នកចូលរួមប្រកួតមកពីសហគមន៍ផង ។



### ជំនួយពីខាងក្រៅ

ប្រសិនបើអ្នកបានចូលទៅទាក់ទងជាមួយនាយកដ្ឋានសិល្បៈជាមួយសាលារៀនណាមួយ ឬបុគ្គលផ្ទាល់ ដូចជាទាក់ទងជាមួយឪពុកម្តាយក្នុងសហគមន៍ជាមួយអ្នកដែលមានទេពកោសល្យផ្នែកសិល្បៈ ហើយមានលទ្ធភាពជួយគាំទ្រនោះ សូមអ្នកពឹងពាក់គាត់ចុះ ។ ការសម្តែងសិល្បៈឱ្យយុវជនក្មេងៗក្នុងក្រុមរបស់អ្នកចូលរួមនោះទេ ពីព្រោះពួកគេប្រហែលត្រូវការ ការលើកទឹកចិត្ត និងការគាំទ្រ ។ ជាពិសេសយុវជនក្មេងៗមិនមានស្មារតី ឬអារម្មណ៍ខ្វាយខ្វល់ចំពោះអ្នកទាំងអស់គ្នាទេ ហើយពួកគេត្រូវការភាពប្រាកដនិយមថា ការខំប្រឹងប្រែងរបស់គេនឹងមិនត្រូវបានចំអកឡកឡឺយ និងមើលងាយឡើយ ។

មធ្យោបាយដ៏ល្អដើម្បីបន្សល់ទុកនូវចំណាប់អារម្មណ៍ទៅលើសិល្បៈគឺការគូររូប ការផាត់ពណ៌ រឿងកំប្លែង និងរឿងដទៃទៀត ។ ប្រសិនបើអ្នកចង់ប្រើទម្រង់សិល្បៈផ្សេងទៀត ដូចជារូបចម្លាក់ បោះពុម្ពរូបភាពលើក្រណាត់

កុំព្យូទ័រ ជំនួយសម្រាប់គូររូបសិល្បៈ និងអ្វីៗដទៃទៀត អ្នកគួរស្វែងរកនូវការគាំទ្រពីខាងក្រៅ។ វត្ថុបំណងនៃមេរៀននេះគឺមិនមែនពង្រីកចំណេះដឹងរបស់អ្នកបង្រៀន ហើយក៏មិនមែនផ្ដោតអារម្មណ៍ជាធំទៅលើការយកចិត្តទុកដាក់អំពីទម្រង់សិល្បៈនោះទេ។ យើងកំពុងស្វែងរកមធ្យោបាយផ្ដត់ផ្ដង់សម្ភារផ្សេងៗដល់យុវជនក្មេងៗដើម្បីឱ្យពួកគេសំដែងគំនិតច្នៃប្រឌិតផ្សេងពីគ្នាដោយខ្លួនឯង។

## ការឧបត្ថម្ភ និងរង្វាន់



ជាផ្នែកមួយនៃការចូលរួមរបស់សហគមន៍ ចូរយើងរៀបចំក្រុមឱ្យទៅកាន់ទីផ្សារកន្លែងរកស៊ីធ្វើជំនួញអង្គការផ្សេងៗ ដែលនៅជិតខាងដើម្បីស្នើសុំការឧបត្ថម្ភជារង្វាន់ដល់ការប្រកួតនេះ។ សូមអ្នកប្រាប់ប្រភេទនៃការប្រកួតឱ្យបានច្បាស់លាស់ ព្រោះវាអាចធ្វើឱ្យពាណិជ្ជករសប្បាយរីករាយ ហើយចូលរួមចំណែក និងផ្ដល់ឱ្យនូវការឧបត្ថម្ភ។ វាមានសារៈសំខាន់ណាស់រឿងដែលអ្នកនិយាយពន្យល់ទៅកាន់ក្រុមរបស់អ្នកមុននឹងពួកគេបែកខ្ញែកគ្នាដើម្បីស្វែងរកអ្នកឧបត្ថម្ភ។ ត្រូវរៀបចំយុទ្ធសាស្ត្រដោយការសរសេរ ឬទូរស័ព្ទជាមុនដើម្បីរៀបចំការប្រជុំ។ ការប្រជុំគួរតែធ្វើឡើងនៅពេលដែលមានអំណោយផលអាចឱ្យអ្នកឧបត្ថម្ភដែលមានសក្ដានុពលចូលរួមបាន។ ក្រុមយុវជនគួរតែសង្ខេបគម្រោងវត្ថុបំណង និងសកម្មភាពរបស់ពួកគេឱ្យបានខ្លី។ ពួកគេត្រូវតែជឿជាក់ថា ខ្លួនគេអាចរៀបចំសកម្មភាពដោយខ្លួនឯងបានល្អសមស្រប។ ប្រសិនបើយុទ្ធសាស្ត្រស្នើសុំការឧបត្ថម្ភរបស់ពួកគេត្រូវបានបដិសេធ ដោយហេតុផលណាមួយ ពួកគេគួរតែសម្រួលបញ្ហានេះ ហើយចាត់ចែងការប្រជុំនៅពេលក្រោយទៀត។ ប្រសិនបើគ្មានបញ្ហាអ្វីទេ ដំណើរការនេះមានន័យថាសមាជិករបស់សហគមន៍បានយល់ដឹងច្បាស់ពីពលកម្មកុមារ ហើយយុវជននៅក្នុងសហគមន៍របស់ពួកគេនឹងបានយល់ដឹងផងដែរ នូវអ្វីដែលគេកំពុងធ្វើ។

អ្នកឧបត្ថម្ភដែលមានសក្ដានុពល គួរត្រូវបានលើកទឹកចិត្តដោយការអះអាងថាឈ្មោះរបស់ពួកគេនិងត្រូវបានផ្សព្វផ្សាយក្នុងពេលប្រកួត ហើយពួកគេនឹងត្រូវបានអញ្ជើញឱ្យចូលរួមទស្សនាការប្រកួតសិល្បៈ និងចូលរួមក្នុងការផ្ដល់រង្វាន់។ លើសពីនេះទៀតអ្នកគួរភ្ជាប់ទៅនឹងការប្រកួតសិល្បៈនូវជំនាញមួយចំនួនដែលយុវជនបានចេះដឹងពីប្រព័ន្ធសារព័ត៌មាន ដូចជាព្រឹត្តិប័ត្រ

សារព័ត៌មានជាដើម ចូរអ្នកផ្តល់ជាដំណឹងទៅប្រព័ន្ធសារព័ត៌មានក្នុងស្រុកឱ្យគេចូលរួមទស្សនាការប្រកួត និងចូលរួមក្នុងពិធីផ្តល់រង្វាន់ផង។ ការផ្សព្វផ្សាយពីការរកស៊ីធ្វើពាណិជ្ជកម្មអាចលើកទឹកចិត្តអ្នកឧបត្ថម្ភដែលមានសក្តានុពលគ្រប់ផ្នែក។ ចូរព្យាយាមរៀបចំឱ្យមានរង្វាន់លេខ ១, ២ និង ៣។ ក្រុមប្រកួតមិនអាចទទួលរង្វាន់បានទាំងអស់គ្នាទេ។ ពួកគេសម្រេចចិត្តឱ្យគេផ្តល់រង្វាន់សម្រាប់ចំណាត់ថ្នាក់លេខ ១ , ២ និង ៣ តែប៉ុណ្ណោះ។

## ដំណើរការវិនិច្ឆ័យ

ចំណុចសំខាន់គឺថាក្រុមប្រកួតត្រូវទទួលខុសត្រូវក្នុងការស្វែងរកការឧបត្ថម្ភ និងរៀបចំការរាយការណ៍តាមប្រព័ន្ធសារព័ត៌មាន និងចាត់ចែងពិធីសម្រាប់ចែករង្វាន់។

ប្រសិនបើអ្នកនឹងរៀបចំការប្រកួតសិល្បៈ អ្នកត្រូវអញ្ជើញមនុស្សក្រុមទី៣ ឱ្យចូលរួមទទួលជ័យជម្នះ។ នេះគឺជាឱកាសដ៏ល្អមួយដើម្បីភ្ជាប់ភ្លាម១នូវសមាជិកផ្សេងទៀតរបស់សហគមន៍ទៅនឹងគម្រោងពលកម្មកុមារ។ ប្រសិនបើអ្នកបានចុះបញ្ជីអ្នកគាំទ្រពីខាងក្រៅសម្រាប់ដំណើរការអប់រំនោះរួចហើយ អ្នកនោះអាចជាមនុស្សម្នាក់នៅក្នុងក្រុមនោះ។ អ្នកត្រូវចុះបញ្ជីនូវអ្នកដែលបានផ្តល់ការឧបត្ថម្ភសម្រាប់ពានរង្វាន់ផងដែរ។ ការងារគួរតែភ្ជាប់ទៅនឹងពាណិជ្ជករសហគមន៍ក្នុងស្រុកដើម្បីលើកទឹកចិត្តពួកគេឱ្យយល់ដឹងច្រើនអំពីពលកម្មកុមារ និងអ្វី១ដែលកំពុងកើតឡើងក្នុងសហគមន៍របស់ពួកគេ។ ប្រសិនបើអ្នកនឹងបើកចំហការប្រកួតនេះដល់ទស្សនិកជនទាំងអស់ ចូរត្រិះរិះពិចារណាដល់ការចុះឈ្មោះសមាជិកក្រុមរបស់អ្នកផ្ទាល់ឱ្យចូលរួមជាគណកម្មការវិនិច្ឆ័យ ប្រសិនបើពួកគេចូលរួម។ ក្រោយពីការងារនេះ ពួកគេនឹងមានអារម្មណ៍ទទួលខុសត្រូវចំពោះគម្រោងរបស់ពួកគេ ហើយពួកគេនឹងមើលឃើញនូវទស្សនៈវិស័យនៃក្រុមរបស់ពួកគេ។ ក្នុងករណីណាក៏ដោយពួកគេនឹងជ្រើសរើសយកផ្នែកការងារណាមួយដ៏ល្អ ឬសមស្របក្នុងនាមជាអ្នកឈ្នះ។ ជាមួយគ្នានេះដែរ អ្នកអាចស្នើទៅយុវជនដទៃទៀតឱ្យធ្វើជាអ្នកវិនិច្ឆ័យផងដែរ។ ឧទាហរណ៍ប្រសិនបើនៅក្នុងសាលារៀនណាមួយ ចូរអ្នកគិតដល់ការជ្រើសរើសគណកម្មការវិនិច្ឆ័យមួយពីថ្នាក់ដទៃទៀត។



## អ្វីៗដែលអ្នកត្រូវការ





- ✓ ក្រដាសសម្រាប់គូរគំនូរ (ទំហំតាមតម្រូវការ) និងពណ៌សម្រាប់ផាត់គំនូរ ក្រដាសគ្រប់ទំហំ
- ✓ ប៊ិច ខ្មៅដៃ និង គូល័រទៀន
- ✓ ប៊ិចហ្វឺត ខ្មៅដៃផាត់ពណ៌ ខ្មៅដៃ និងជក់
- ✓ សៀវភៅសិល្បៈ និងពលកម្មកុមារ ឬសៀវភៅស្តីពីការគាបសង្កត់នឹងជួយយុវជនឱ្យមានគំនិតចេះនឹកស្មានបង្កើតរូបភាពផ្ទាល់ខ្លួនរបស់គេ។
- ✓ បន្ទប់ ឬកន្លែងមួយដែលមានក្រលាផ្ទៃធំមានជញ្ជាំងអាចប្រើប្រាស់បាន។
- ✓ ជញ្ជាំងទំនេរអាចព្យួរផ្ទាំងគំនូរ ឬសិល្បៈ

ការពិតទៅប្រសិនបើអ្នកបើកចំហការប្រកួតសិល្បៈនេះសម្រាប់សហគមន៍ទាំងមូល អ្នកមិនត្រូវគិតថា អ្នកអាចផ្តល់សម្ភារឧបទ្ទេសសម្រាប់បេក្ខជនទាំងអស់នោះទេ។ សម្ភារឧបទ្ទេសដែលបានចុះក្នុងបញ្ជីខាងលើគឺសម្រាប់ការងារក្រុមផ្ទាល់ខ្លួនរបស់អ្នក។

## ការចាប់ផ្តើម

ប្រហែលជាមានហេតុផលផ្សេងគ្នាជាច្រើននាំឱ្យមានសំណួរថា ហេតុអ្វីបានជាអ្នកសម្រេចចិត្តដាក់មេរៀននេះឱ្យគេអនុវត្ត ប៉ុន្តែគំនិតមូលដ្ឋានគឺជួយបង្កើនការយល់ដឹងសម្រាប់យុវជន និងលើកទឹកចិត្តពួកគេឱ្យចេះផ្ទេរការយល់ដឹងជូនទៅសហគមន៍របស់ពួកគេ ហើយបង្កើតសកម្មភាពរួមបញ្ចូលគ្នា ។ ហេតុដូចនេះ គំនិតប្រជាជនដទៃទៀតមានការយល់ដឹងអំពីពលកម្មកុមារ និងអ្វីដែលគួរត្រូវបានគេបញ្ឈប់កុំឱ្យមានសកម្មភាពនឹងក្លាយជាប្រធានបទទូទៅនៃការប្រកួតសិល្បៈ។ ប៉ុន្តែផ្ទុយទៅវិញ អ្នកនឹងត្រូវការផ្តល់នូវប្រធានបទដ៏ពិស្តារ និងការសង្ខេបដ៏ខ្លីមួយសម្រាប់បេក្ខជនដែលមានសក្តានុពលដូចនេះពួកគេយល់ទាំងអស់គ្នានូវអ្វីដែលឆ្លុះបញ្ចាំងចេញពីការងារសិល្បៈរបស់ពួកគេ។ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏ល្អជាច្រើនសម្រាប់បណ្តុះគំនិតគឺការរៀបចំវគ្គពិភាក្សារួមគ្នាមួយជាមួយក្រុមអ្នក ចូរអ្នកសួរពួកគេនូវអ្វីដែលពួកគេគិតឃើញពីប្រធានបទនៃការប្រកួតរបស់គេ។ គោលបំណងរបស់ប្រធានបទចំណងជើង ឬពាក្យស្លោកត្រូវតែក្តោបស្មារតីនៃគម្រោង។



កាលណាអ្នកបានបង្កើតប្រធានបទដែលគេអាចទទួលបាន អ្នកត្រូវតែសង្ខេបឯកសារព្រាងមួយសម្រាប់ចូលរួមការងារទាំងអស់នោះ។ តាមការពិតទៅឯកសារសង្ខេបមួយបែបនេះមិនមានសារៈសំខាន់ទេ ប្រសិនបើការប្រកួតនេះត្រូវធ្វើឡើងតែនៅក្នុងក្រុមការងាររបស់យើងនោះ។ សម្រាប់ទស្សនិកជនទាំងឡាយ អ្នកត្រូវ តែពន្យល់ និងណែនាំឱ្យបានច្បាស់នូវអ្វីដែលអ្នកចង់ឱ្យពួកគេធ្វើ។ ចូរអ្នកស្នើសុំអ្នកស្ម័គ្រចិត្តក្នុងក្រុមរបស់អ្នកឱ្យជួយសង្ខេបឯកសារពង្រាងឱ្យបានពាក់កណ្តាលមួយចំហៀងក្រដាស A4។ ឯកសារនេះគួរពិពណ៌នាអំពីស្ថិតិកុមារមួយចំនួនទម្រង់អាក្រក់របស់វា និងការប៉ះពាល់ដល់ការធំធាត់របស់ក្មេង ការអប់រំសភាវៈល្អៗនិងអ្វីៗផ្សេងទៀតជាច្រើន។ ក្រៅពីនេះយើងគួរពណ៌នាផងដែរ អំពីប្រធានបទសម្រាប់ប្រកួត និងពន្យល់អំពីច្បាប់នៃការចូលរួមប្រកួត។

ជាទូទៅឯកសារសង្ខេបត្រូវតែបង្ហាញផ្ទៃកលំអិតៗ និងកំណត់ពេលវេលាបិទវគ្គសម្រាប់ឱ្យអ្នកចូលរួមឱ្យបានច្បាស់លាស់។ ពេលកំនត់គួរតែខ្លីដើម្បីរក្សាតម្លៃការប្រកួត។ ការកំណត់ពេលវែងសម្រាប់ការរៀបចំការងារនេះអាចនាំឱ្យអ្នកទាំងអស់គ្នាអស់កំលាំងនឿយហត់ ហើយនាំឱ្យមានការប៉ះពាល់ដល់មេរៀននេះទៀតផង។ ជាមួយគ្នានេះដែរ ក្នុងឯកសារសង្ខេបអ្នកគួរតែចុះបញ្ជីរាល់រង្វាន់ដែលអ្នកប្រមូលផ្តុំបាន។

ឯកសារសង្ខេបគំរូមួយត្រូវបានបញ្ចូលជាឧបសម្ព័ន្ធរបស់មេរៀនដើម្បីផ្តល់ឱ្យអ្នកនូវការយល់ដឹងអំពីប្រភេទ និងកំរិតព័ត៌មានដើម្បីចូលរួមការប្រកួតសិល្បៈ។ សូមបញ្ជាក់ថា ឧបសម្ព័ន្ធនេះមានបំណងប្រាប់ព័ត៌មានតែប៉ុណ្ណោះ ហើយអ្នកនិងក្រុមរបស់អ្នកគួរបង្កើតឯកសារសង្ខេបដ៏ល្អមួយដែលសមស្របទៅនឹងបរិស្ថានបរិបទប្រពៃណី និងវប្បធម៌របស់អ្នក។

## ការរៀបចំក្រុម



យើងត្រូវលើកទឹកចិត្តដល់យុវជននៅក្នុងក្រុមឱ្យបង្ហាញគំនិតផ្ទាល់ខ្លួនរបស់គេម្នាក់ៗដែលមិនមែនជាគំនិតរបស់ក្រុម។ ប្រសិនខ្វះសម្ភារឧបទ្ទេសយើងអាចឱ្យបុគ្គលម្នាក់អាចបង្កើត សម្ភារសិល្បៈផ្ទាល់ខ្លួនរបស់គេបាន។ ប្រជាជន២នាក់អាចសួរគ្នាថា តើបើពួកគេអាចធ្វើការរួមគ្នាតាមគំនិតដែលពួកគេបានលើកឡើងរួមគ្នាដែរឬក៏មិនបាន។ ឧទាហរណ៍ ជាមួយគំនិតផ្ដួចផ្ដើមរបស់គេ ប្រហែលជាប្រសើរណាស់ បើគេចេះតែធ្វើដំណើរទៅមុខដោយសេរី ហើយគេនឹងឃើញនូវអ្វីដែលកើតមានឡើងមក។ ចូរអ្នករក្សាការខំប្រឹងប្រែង ហើយត្រូវជឿជាក់ថាការងារកំពុងធ្វើគឺត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ ។ ប្រសិនការងារក្លាយទៅជាការជ្រើសរើសយកមេរៀននេះចេញពីសៀវភៅ ចូរអ្នកបែងចែកក្រុមម្ដងទៀត។ យុវជនក្មេងៗប្រហែលជាព្យាយាម និង ស្វែងរកមធ្យោបាយមួយដែលពួកគេអាចធ្វើបាន។

## សកម្មភាព ១ :

## ប្រកួតសិល្បៈជាក្រុម

*បង្រៀន១ពេលដើម្បីបង្កើតក្រុមការងារ និងទទួលការស្នើសុំ និងបង្រៀន១ពេល ដើម្បីពិនិត្យ និងវិនិច្ឆ័យអ្នកចូលរួមប្រកួត ។*



ប្រសិនបើបានគេសម្រេចចិត្តកំនត់ឱ្យមានការប្រកួតសិល្បៈតែមួយក្រុម ចូរអ្នកចំណាយពេល១០នាទីនៅខាងដើមវគ្គ ដែលទាក់ទងនឹងព័តិមានដែលត្រូវបានសិក្សាយ៉ាងយូរអំពីពលកម្មកុមារ ។ បន្ទាប់មកចូរពិភាក្សាពីប្រធានបទមួយសម្រាប់ការងារសិល្បៈដែលមនុស្សគ្រប់រូបនិងធ្វើវាបន្ត ។ ចូរត្រូវពិភាក្សារកទម្រង់សិល្បៈបែបណាដែលអាចអនុវត្ត ហើយផ្នែកណាមួយនៃការងារប្រកួតដែលចង់បង្កើតឱ្យមាន ។ ឧទាហរណ៍ តើក្រុមប្រកួតមួយណាចង់ផលិតផ្ទាំងរូបភាពមួយដែលផ្សព្វផ្សាយពីគម្រោងរបស់ពួកគេដែរឬទេ? តើវត្ថុបំណងនេះពិតជាងាយស្រួលអាចឱ្យគេបង្កើតផ្ទាំងសិល្បៈល្អៗ ដែលអាចព្យួរបង្ហាញលើជញ្ជាំងក្នុងថ្នាក់រៀនឬក្នុងសាលតាំងពិពណ៌ពិសេសណាមួយដើម្បីលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ដែរឬទេ?

គ្រាដែលទម្រង់សិល្បៈ និងវត្ថុបំណងត្រូវបានគេយល់ព្រមហើយ អ្នកគួរតែជំរុញឱ្យក្រុមអ្នកចាប់ផ្តើមការងាររបស់ពួកគេ ហើយកំណត់ពេលវេលាឱ្យពួកគេបញ្ចប់ការងារឱ្យបានច្បាស់លាស់ ។ អ្នកអាចទុករយៈពេល ២សប្តាហ៍ឱ្យពួកគេធ្វើការងារដើម្បីប្រកួតតាមពេលម៉ោងផ្ទាល់ខ្លួនរបស់គេ ឬអ្នកអាចបន្ថែមវគ្គសម្តែងមួយទៀតឱ្យក្រុមរបស់អ្នកបន្តការរៀបចំការងារសិល្បៈរបស់ពួកគេ ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ។

នៅពេលដែលគ្រប់ផ្នែកនៃការងារត្រូវបានបញ្ចប់ហើយនោះ ចូរបិទការងារទាំងអស់នោះលើជញ្ជាំងមួយក្នុងបន្ទប់ដែលអ្នកកំពុងធ្វើការ ហើយហៅគណកម្មការវិនិច្ឆ័យដែលបានជ្រើសរើសពីមុនមក ។ ចូរអ្នកជំរុញក្រុមឱ្យចំណាយពេលវេលាដើម្បីពិនិត្យពិច័យ និងវិភាគយ៉ាងហ្មត់ចត់លើផ្នែកនីមួយៗនៃការងារ ។ ចូរស្វែងរកការពន្យល់ និងការយល់ដឹងយ៉ាងជ្រៅជ្រះរបស់ពួកគេដើម្បីជំរុញការពិភាក្សាឱ្យមានដំណើរការល្អ ។ អ្នកប្រហែលយល់ច្បាស់ថាអ្នកបានបង្ហាញទេពកោសល្យសិល្បៈពិតប្រាកដមួយចំនួនរបស់អ្នក ។

## សកម្មភាព ២ : ការប្រកួតសិល្បៈសហគមន៍

ប្រជុំ១ពេលដើម្បីរៀបចំការប្រកួត និងប្រជុំ១ពេលសម្រាប់ការរៀបចំការប្រកួតជាសាធារណៈដើម្បីអង្កេត និងវិនិច្ឆ័យអ្នកចូលរួមប្រកួត។

ប្រសិនបើការប្រកួតសិល្បៈត្រូវបានគេបើកចំហសម្រាប់មនុស្សទាំងអស់ក្នុងសហគមន៍នោះ ផ្ទាំងរូបភាពសាមញ្ញមួយគួរត្រូវបានបង្កើត និងផ្សព្វផ្សាយឱ្យមានលក្ខណៈទូលំទូលាយបើអាចធ្វើទៅបាន។ ផ្ទាំងរូបភាពគួរតែពិពណ៌នាយ៉ាងសង្ខេបពីការប្រកួត និងអធិប្បាយឱ្យបានពិស្តារពីរង្វាន់។ បន្ទាប់មកផ្ទាំងរូបភាពគួរតែត្រូវបានគេថតចម្លង ហើយដាក់នៅកន្លែងសំខាន់ៗគ្រប់ទិសទីតាមរយៈសហគមន៍ដែលទាក់ទង។ ឧទាហរណ៍ នៅសាលារៀន ឬក្លឹបយុវជន។ ចូរតម្រូវឱ្យក្រុមរៀបចំថតចម្លង និងចែកចាយផ្ទាំងរូបភាព។ អនុញ្ញាតឱ្យពួកគេដឹងថា ពួកគេអាចចូលរួមការប្រកួតនេះផងដែរ។ នៅពេលដែលការរៀបចំត្រូវបានគេអនុម័ត ក្រុមវិនិច្ឆ័យត្រូវទាមទារធ្វើការអង្កេតមើលការងារសិល្បៈនេះ។ បង្កើតកិច្ចសន្យាដ៏ធំមួយចំពោះការប្រកួតនៅពេលណាអ្នកឈ្នះត្រូវបានគេជ្រើសរើសសម្រាប់ពិធីសាធារណៈមួយដើម្បីផ្តល់រង្វាន់។ នេះជាពេលដែលអាចជឿជាក់ថា អ្នកតំណាងសារព័ត៌មានក្នុងស្រុកមានវត្តមានដើម្បីធានាបញ្ជាក់ថាទាំងអ្នកឈ្នះ និងបញ្ហាពលកម្មកុមារត្រូវបានទទួលស្គាល់ជាសាធារណៈ។ ចូរកុំភ្លេចថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភការប្រកួតក្នុងការធ្វើទំនាក់ទំនងជាមួយសារព័ត៌មានសម្រាប់ការប្រកួតនេះ ហើយអ្នកគួរធ្វើការជាមួយក្រុមក្នុងការរៀបចំការពិភាក្សាចុងបញ្ចប់ក្រោមទិដ្ឋភាពខាងលើនេះ។



## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



- ចូរកុំបង្កើតទិដ្ឋភាពប្រកួតដោយការបង្ខំឱ្យធ្វើតាមមេរៀននេះ។ ត្រូវមានគំនិតអនុញ្ញាតឱ្យយុវជនក្មេងៗមានពេលវេលា ទីកន្លែង និងសម្ភារដើម្បីបង្ហាញភាពស្មោះត្រង់របស់ពួកគេតាមរយៈសិល្បៈ។ ប្រសិនការប្រកួតត្រូវគេបង្ខំឱ្យធ្វើនោះ ប្រជាជនប្រហែលជាមានអារម្មណ៍ថា អ្វីដែលពួកគេបង្កើតប្រហែលជាមិនសមស្រប និងលក្ខណៈប្រកួតនេះទេ។
- ចូរជឿជាក់ថា បុគ្គលនីមួយៗបានចូលរួម។ យុវជនក្មេងៗអាចត្រូវបានគេការពារ ហើយអ្នកត្រូវតែប្រើប្រាស់លំហាត់ទាំងនោះដើម្បីចាប់ផ្ដើមបំបាត់ភាពរអាក់រអួលនេះ។



- ចូរជឿជាក់ថា យុវជនក្មេងណាក៏ដោយដែលអ្នកបានទទួលខុសត្រូវគឺត្រូវបានគេណែនាំដោយសង្ខេប និងយ៉ាងត្រឹមត្រូវមុនពេលគាត់ ឬនាងបានចាកចេញពីសហគមន៍ដើម្បីស្វែងរកការឧបត្ថម្ភសម្រាប់ការប្រកួត។
- ចូររក្សាពេលកំណត់ និងថែរក្សារាល់កម្លាំងចលករ
- ចូរអញ្ជើញអ្នកឧបត្ថម្ភ និងអ្នកដទៃទៀតដើម្បីវិនិច្ឆ័យ និងធ្វើពិធីជូនរង្វាន់។
- ចូរជឿជាក់ថា អ្នកបានរក្សាគ្រប់ការងារសិល្បៈដែលបានរៀបចំ ហើយបានស្វែងរកមធ្យោបាយមួយ ដើម្បីផ្សព្វផ្សាយការងារដ៏ច្រើននេះតាមលទ្ធភាពជាមួយសហគមន៍។

### ការពិភាក្សាបញ្ចប់បង្រៀន១ពេល

ការប្រកួតសិល្បៈគឺជាមេរៀនដ៏សប្បាយមួយ។ យុវជនក្មេងៗក្នុងក្រុមរបស់អ្នកនឹងប្រហែលជាចូលចិត្តបង្កើតការងារសិល្បៈផ្ទាល់ខ្លួនរបស់ពួកគេ ហើយនឹងចូលចិត្តមើលការងារប្រជាជនដទៃទៀត ជាពិសេសក្នុងតួនាទីជាអ្នកវិនិច្ឆ័យ។ ប៉ុន្តែផ្ទុយទៅវិញនៅពេលការងារនេះត្រូវរៀបចំ ហើយអ្នកបានត្រឡប់មកនៅជាមួយក្រុមអ្នក ចូរអ្នកចំណាយពេលសមល្មមដើម្បីអង្គុយ និងនិយាយលេងសើចជាមួយពួកគេក្នុងពេលដែលពួកគេក្រឡេកមើលផ្នែកផ្សេងៗនៃការងារដែលត្រូវបានគេបិទលើជញ្ជាំងក្នុងបន្ទប់របស់ពួកគេ។

ការរៀបចំមួយចំនួនហាក់ដូចជាមានតម្លៃខ្ពស់ ហើយត្រូវបានយកចិត្តទុកដាក់ដោយមនុស្សគ្រប់គ្នា។ ប៉ុន្តែវាជាការចាំបាច់ដែលរាល់ការរៀបចំនីមួយៗត្រូវបានពិនិត្យពិច័យ និងវាយតម្លៃរកភាពស្មោះត្រង់។ ពួកគេអាចយល់ច្បាស់នូវអ្វីដែលប្រជាជនបានគិតនិងពួកគេគិតនៅក្នុងចិត្តពីពលកម្មកុមារ។ គេមិនអាចចៀសផុតបានឡើយនូវការរៀបចំមួយចំនួនដែលមិនហ្មត់ចត់ ប៉ុន្តែវាជាការចង្អុលបង្ហាញពីការយល់ដឹងពីខ្លួនឯងដ៏ច្រើនលើសលប់ ស្តីពីផ្នែកណាមួយនៃការងារសិល្បៈជាជាងការបង្ហាញដោយគ្មានទទួលការចាប់អារម្មណ៏។ យុវជនក្មេងៗមួយចំនួននឹងមិនអាចថតចម្លងដោយងាយស្រួលពីការពិតដ៏ឥតល្បើងនៃពលកម្មកុមារ ហើយពួកគេនឹងបំភ្លេចនូវអារម្មណ៏ពិតមួយក្រោយពីការប្រឈមមុខចំពោះភាពព្រងើយកន្តើយ និងភាពមិនស្មោះត្រង់នៃការងារនោះ។

ចូរសួរទៅក្រុមអ្នកថា តើរូបភាពណាមួយដែលពួកគេចូលចិត្ត ឬមួយណាដែលទាក់ទាញចំណាប់អារម្មណ៏គេយ៉ាងខ្លាំង។ ហេតុអ្វីបានជាពួកគេចូលចិត្តរូបភាពពិសេសមួយនេះម្លេះ? តើប្រលោមលោកនេះនិយាយពីអ្វី? តើរូបភាពនៃសេចក្តីសង្ឃឹមអាចត្រូវបានគេរកឃើញក្នុងការងារសិល្បៈមួយណាដែរឬទេ? តើការរៀបចំនេះបានបង្ហាញនូវភាពខ្វះខាតនៃការយល់ដឹងចំពោះបញ្ហាពលកម្មកុមារដែរឬទេ? ហេតុអ្វីបានជាក្រុមគិតដូច្នេះ? តើពួកគេគិតថា មនុស្សដែលមានវ័យស្មើនិងគេមិនអាចយល់ដឹងពីបញ្ហាដែលជាប់ទាក់ទងនេះដែរឬទេ? ប្រសិនបើនេះជាករណីមួយ តើពួកគេមិនគិតថាមនុស្សវ័យស្មើគេគួរតែយល់ដឹងពីពលកម្មកុមារឬ? តើពួកយើងអាចធ្វើការងារនេះយ៉ាងដូចម្តេច? តើពួកយើងធ្វើវាយ៉ាងដូចម្តេចដើម្បីឱ្យប្រជាជនយល់ដឹងបានច្រើនថាអ្វីទៅដែលហៅថាពលកម្មកុមារ និងតើពលកម្មកុមារធ្វើយ៉ាងដូចម្តេចចំពោះកុមារ?

តើយើងអាចធ្វើយ៉ាងដូចម្តេច? នៅចុងបញ្ចប់វគ្គនេះគឺជាអ្វីដែលយើងទទួលបានតើមនុស្សម្នាក់ និងមនុស្សគ្រប់រូបអាចធ្វើដូចម្តេច ដើម្បីធ្វើឱ្យយុវជនយល់ដឹងច្រើន ហើយចង់ធ្វើអ្វីមួយដើម្បីជួយពួកគេក្នុងពេលត្រូវការ? ចូរចងចាំថា យើងចង់រៀបបញ្ជីឈ្មោះជំនួយយុវជនក្មេងទាំងអស់នោះទុកដូចជាភ្នាក់ងារសម្រាប់ការប្រើប្រាស់កម្លាំងសង្គម និងផ្លាស់ប្តូរសង្គម។ យើងត្រូវជួយគេ ក្នុងតួនាទីនេះដោយផ្តល់សម្ភារឧបទ្ទេសដើម្បីលើកកម្ពស់ការយល់ដឹង និងការ ចូលរួមការងាររបស់ពួកគេ។



## ការវាយតម្លៃ និងសកម្មភាពបន្ត



ក្នុងរយៈពេលនៃការចង្អុលបង្ហាញមេរៀននេះ យើងមានលទ្ធផលពិសេសពិតប្រាកដដែលអាចសម្គាល់បានក្នុងរយៈពេលដ៏យូរមិនថា ពួកគេបានជួបប្រទះ ឬក៏អត់នោះទេ។ យុវជនក្មេងៗណាមួយក្នុងក្រុមនិងបង្កើតការងារសិល្បៈមួយ ដែលពិពណ៌នាពីទស្សនទាននៃពលកម្មកុមារ។ ការងារដែលបានបង្កើតនេះនឹងពឹងផ្អែកខ្លះលើចរិតលក្ខណៈរបស់បុគ្គលដែលទាក់ទង ប៉ុន្តែពឹងផ្អែកផងដែរទៅលើមេរៀនដែលត្រូវបានអនុវត្ត និងទៅលើទំនាក់ទំនងដែលអាចបង្កើតជាមួយក្រុម។

មិនជាបញ្ហាអ្វីទេ ចំពោះការប្រកួតគ្រប់ប្រភេទដែលត្រូវបានរៀបចំការអនុវត្តបន្តបន្ទាប់តាមមេរៀននេះដើម្បីពង្រឹងទំនុកចិត្ត និងសម្ព័ន្ធភាពរបស់ក្រុម និងជួយពួកគេឱ្យបង្កើតការតាំងពិពណ៌នៃការងារសិល្បះមួយដែលបានរៀបចំ សម្រាប់ការប្រកួត។ ដូចនេះ ការតាំងពិពណ៌មួយនឹងមានឥទ្ធិពលធំក្នុងសហគមន៍ ឧទាហរណ៍ ក្នុងសាលារៀន ឬក្លឹបយុវជន។ ចូរឱ្យក្រុមចាត់ចែងរៀបចំមូលនិធិ ប្រមូលកាហ្វេតែ ឬការទទួលភេសជ្ជៈជុំវិញការតាំងពិពណ៌។ ការងារប្រហែលជាត្រូវបានលក់ដេញថ្លៃ ហើយវត្តមាននៃការលក់ដេញថ្លៃរបស់ប្រជាជនអាចបញ្ជាក់ថា ការប្រមូលមូលនិធិនេះ នឹងត្រូវបានប្រើសម្រាប់សកម្មភាពពលកម្មកុមារ ឬត្រូវបានបរិច្ចាកទៅឱ្យសាលាដើម្បីស្តារឱ្យបានល្អនូវពលកម្មកុមារ។

ការតាំងពិពណ៌នៃការងារសិល្បៈនេះ និងការលក់ដេញថ្លៃប្រហែលអាចជាស្នូលនៃយុទ្ធនាការលើកកម្ពស់ការយល់ដឹងបន្ថែមជាមួយសហគមន៍ក្នុងស្រុកហើយអ្នកគួរធ្វើឱ្យមានលក្ខណៈទូលំទូលាយជាមួយប្រព័ន្ធសារព័ត៌មានក្នុងស្រុក និងជាតិផងដែរ។ នេះគឺជាការចង្អុលបង្ហាញនៃភាពជោគជ័យដ៏ធំមួយ ហើយវានឹងជួយបង្កើតទិដ្ឋភាពនិរន្តរភាពយ៉ាងសំខាន់មួយនៃមេរៀននេះ។

យើងនឹងមានឱកាសច្រើន ក្នុងដំណើរការអនុវត្តមេរៀនពលកម្មកុមារទាំងនេះ នៅពេលការងារសិល្បៈមានប្រយោជន៍ច្រើន ហើយមានប្រសិទ្ធភាពសម្រាប់ការលើកកម្ពស់បរិស្ថានផ្សេងៗ។ ឧទាហរណ៍ ប្រសិនបើអ្នកអនុវត្តមេរៀនល្ខោនជាយថាហេតុ អ្នកប្រហែលចង់តុបតែងឆាក ឬរោងល្ខោនជាមួយការងារសិល្បៈមួយចំនួនដែលបានបង្កើតសម្រាប់ការប្រកួតនេះ។ ការងារនឹងជួយឱ្យប្រជាជនបាន

យល់ពីបញ្ហាដែលពាក់ព័ន្ធ ហើយអាចឱ្យអ្នករៀបចំរោងល្ខោន និងបង្កើតប្រធានបទនៃពលកម្មកុមារពិតមួយសម្រាប់ការប្រកួត។ ហេតុដូចនេះ ចូរជឿជាក់ថា អ្នកអាចថែរក្សាគ្រប់គ្រង់ការរៀបចំយ៉ាងសុវត្ថិភាពនៅគ្រប់ទីកន្លែងតាមលទ្ធភាពដែលធ្វើទៅបាន។ មេរៀននេះគឺសាមញ្ញប៉ុន្តែប្រសិទ្ធភាពផ្តោតទៅលើការបង្កើនការយល់ដឹងអំពីបញ្ហាពលកម្មកុមារក្នុងចំណោមយុវជនក្មេងៗ ជាមួយគ្នានេះផងដែរមេរៀននេះជាសម្ភារឧបទ្ទេសដ៏មានប្រសិទ្ធភាពមួយសម្រាប់ណែនាំប្រជាជនវ័យក្មេងដើរក្នុងផ្លូវដ៏ល្អមួយ។ ជារឿយៗប្រជាជនបានបង្ហាញពីភាពស្ម័គ្រចិត្ត និងភាពស្មោះត្រង់ក្នុងសិល្បៈច្រើនជាងការនិយាយ ឬការសរសេរ។



ក្នុងពេលធ្វើការជាមួយយុវជនវ័យក្មេង វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឱកាសឱ្យពួកគេធ្វើការចាប់អារម្មណ៍ដោយមិនបានគំរាមកំហែងតួនាទីរបស់គេក្នុងក្រុម ឬធ្វើឱ្យពួកគេលេចធ្លោដោយវិធីណាមួយ។ សិល្បៈអាចឱ្យពួកគេធ្វើដូច្នេះបាន។ ជាមួយមេរៀននេះ យើងនឹងអាចឱ្យយុវជនក្មេងៗ ចាប់ផ្តើមរកឱ្យឃើញនូវតួនាទីថ្មីមួយរបស់ពួកគេ ដូចជាគ្រូបង្រៀន និងភ្នាក់ងារសហគមន៍ សម្រាប់ការប្រមូលកម្លាំងសង្គម។ មេរៀននេះត្រូវបានគេធ្វើក្នុងមធ្យោបាយដ៏ ប្រពៃមួយដោយការភ្ជាប់ពួកគេទៅនឹងការរៀបចំការប្រកួតមួយ ហើយរៀបចំ មេរៀនសង្ខេបដែលបេក្ខជនដែលប្រាថ្នាចូលរួម។ លើសពីនេះទៀតពួកគេនឹង ចាប់ផ្តើមចាកចេញពីសហគមន៍ដ៏ធំដើម្បីស្វែងរកអ្នកឧបត្ថម្ភដែលមានសក្តានុពលសម្រាប់ការប្រកួត ហើយនិងពន្យល់នូវអ្វីដែលមានក្នុងគម្រោងរបស់ពួកគេ និងពន្យល់ថា តើហេតុដែលនាំឱ្យពួកគេកំពុងស្វែងរកការឧបត្ថម្ភគាំទ្រ។ នេះគឺជា ការចាប់ផ្តើមនៃដំណើរការសិក្សាដ៏សំខាន់មួយ។

ហេតុដូច្នេះ មេរៀនណាមួយដែលគេយកមកប្រើជាបន្ទាប់គឺសម្រេចទៅតាមតែចិត្តអ្នក និងក្រុមរបស់អ្នកទេ ហើយមេរៀននឹងពឹងផ្អែកទាំងស្រុងលើកាលវិភាគ និងយុទ្ធសាស្ត្រផ្ទាល់ខ្លួនរបស់អ្នក។ អ្នកអាចផ្លាស់ប្តូរមេរៀននេះជាមេរៀនរូបភាព ឬមេរៀនសរសេរច្នៃប្រឌិត ប្រសិនបើអ្នកមិនទាន់បានអនុវត្តវានោះ។

# ឧបសម្ព័ន្ធ១

## ការប្រកួតសិល្បៈ

*គម្រោងស្រ្តីមនៃពលកម្មកុមារ (ដែលរៀបចំក្នុងមហាវិទ្យាល័យសហគមន៍ Scariff នៅសាធារណរដ្ឋ អៀរឡង់ ក្នុងខែ មីនា ឆ្នាំ ២០០១។)*

## ព័ត៌មានលំអិត

ការប្រកួតត្រូវបានបើកចំហសម្រាប់បេក្ខជនគ្រប់វ័យនៅមហាវិទ្យាល័យ។ ប៉ុន្តែការប្រកួតនេះគឺបើកចំហសម្រាប់តែនិស្សិតនៅមហាវិទ្យាល័យតែប៉ុណ្ណោះ។ ថ្ងៃកំណត់សម្រាប់ការរៀបចំគឺនៅម៉ោង ១២ ថ្ងៃសុក្រ ទី ២៩ ខែ មីនា ឆ្នាំ ២០០១។ គ្មានការរៀបចំណាមួយអាចត្រូវបានគេយល់ព្រមក្រោយថ្ងៃកំណត់នោះទេ។ ការរៀបចំការងារសិល្បៈត្រូវតែធ្វើដោយផ្ទាល់ជាមួយគ្រូសិល្បៈ ឬការិយាល័យសិក្សានៅតាមសាលា។

សិល្បករត្រូវស្នើសុំបោះពុម្ពឈ្មោះ អាស័យដ្ឋាន និងអាយុរបស់ពួកគេនៅផ្នែកខាងខ្នងនៃការរៀបចំ។

គ្រប់ការងារត្រូវរក្សាភាពដើម ឧទាហរណ៍ គ្មានការផ្តិត គូរចម្លងរូបភាព ឬត្រូវបានយល់ព្រមឡើយ។ ការរៀបចំវាមិនសំខាន់ទៅលើការគូរ ឬក៏ផាត់ពណ៌លើរូបនោះទេ។ ការងារនិងត្រូវបានគេវិនិច្ឆ័យលើខ្លឹមសារសិល្បៈ និងភាពជាប់ទាក់ទងរបស់វាទៅនឹងប្រធានបទនៃការប្រកួត។

ការរៀបចំផ្តល់ជ័យជំនះនឹងមិនត្រូវបានច្រានចោលឡើយ។

គណៈកម្មាការនៃក្រុមវិនិច្ឆ័យទាំង៥នឹងបញ្ចូលគ្រូសិល្បៈ អ្នកសម្របសម្រួលគម្រោង និងនិស្សិតឆ្នាំទី៤ ៣រូបដែលត្រូវបានផ្តល់ឈ្មោះមក។ ការសម្រេចចិត្តត្រូវកំណត់យកអ្នកលេខ ១,២,៣,តែប៉ុណ្ណោះ។

រង្វាន់គឺសូកូឡា៣ដុំសម្រាប់អ្នកលេខ១ ២ដុំសម្រាប់អ្នកលេខ២ និង១ដុំសម្រាប់អ្នកលេខ៣។ ឈ្មោះអ្នកឈ្នះ និងត្រូវបានគេបិទប្រកាសនៅសាលារៀននៅថ្ងៃសុក្រ ទី ៥ ខែ មេសា ឆ្នាំ ២០០១។ ការបង្ហាញជាផ្លូវការ និងត្រូវបានគេ ធ្វើសម្រាប់អ្នកឈ្នះនៅសាលារៀន នៅថ្ងៃ ច័ន្ទ ទី ៨ ខែ មេសា ឆ្នាំ ២០០១។

អ្នកចូលរួមត្រូវបានសុំឱ្យបង្កើតផ្ទាំងរូបភាពមួយស្តីពីអាជីវកម្មពលកម្មកុមារដោយមានអក្សរកាត់ SCREAM។ របៀបបង្កើតផ្ទាំងរូបភាពសម្រាប់ការចូលរួមប្រកួតស្រេចតែបុគ្គលម្នាក់ៗទេ។ បុគ្គលម្នាក់ត្រូវបានសុំឱ្យបង្ហាញពីទស្សនទាននៃពលកម្មកុមារ និងការប្រមូលផ្តុំរបស់ពួកគេតាមមធ្យោបាយដ៏សមស្រមតាមពាក្យ ឬគំនិតរបស់ SCREAM។ ផ្ទាំងរូបភាពអាចត្រូវបានរៀបចំលើគ្រប់ក្រដាសពណ៌គ្រប់ទំហំ ប៉ុន្តែមិនតូចជាងក្រដាស A4ទេ។

ខាងក្រោមនេះ គឺជាព័ត៌មានលំអិត និងពិស្តារស្តីពីពលកម្មកុមារ និង SCREAM ដែលជួយសិល្បករឱ្យយល់ពីទស្សនទានដែលពាក់ព័ន្ធ។ គណៈកម្មការវិនិច្ឆ័យត្រូវបញ្ចូល SCREAM ដាក់បញ្ចូលទៅក្នុងគ្រប់រូបភាព និងក្នុងមធ្យោបាយច្នៃប្រឌិតដើម្បីបង្ហាញថាយុវជនក្មេងៗអាចធ្វើអ្វីមួយអំពីពលកម្មកុមារ។

## ប្រធានបទនៃការប្រកួត

ពលកម្មកុមារគឺជាការពិពណ៌នាមួយអំពីកុមារជុំវិញពិភពលោកដែលត្រូវបានគេតម្រូវ និងបង្ខំឱ្យធ្វើការដើម្បីរស់។ មានក្មេងប្រមាណ ២៤៥ លាននាក់ ជុំវិញពិភពលោកដែលធ្វើការពេញម៉ោង ឬពាក់កណ្តាលម៉ោង ហើយ ១៧០ លាននាក់ នៃក្មេង ទាំងអស់នោះធ្វើការក្នុងលក្ខខណ្ឌធ្ងន់ធ្ងរ។

ការងារដែលពួកគេធ្វើមានលក្ខណៈប្រែប្រួលដូចជាអ្នកបម្រើតាមផ្ទះ ទាហានក្មេង ពេស្យាចារ្យ ការងារកសិកម្មការងារជីករ៉ែ ការងារសំណង់ ការងារវ៉ៃថ្ម ការងារដុតឥដ្ឋ ឧស្សាហកម្មគាស់ថ្ម និងការងារដទៃទៀត។ ភាពខុសគ្នារវាងក្មេងម្នាក់ក្នុងប្រទេសអឿឡង់ដែលធ្វើការដើម្បីបានប្រាក់ដាក់ហោប៉ៅ និងកុមារពលកម្ម គឺជាមូលដ្ឋាននៃសិទ្ធិមនុស្ស សេរីភាពនៃការជ្រើសរើស។ កុមារពលកម្មគ្មានការជ្រើសរើសទេ។ ពួកគេធ្វើការ ហើយបើមិនធ្វើការ គ្រួសាររបស់ពួកគេនឹងស្លាប់ដោយគ្មានអាហារហូប។ ពួកគេបានបាត់បង់នូវភាពកុមារ និងមិនបានទទួលនូវការអប់រំឡើយ។ ក្នុងចំនួននៃករណីដ៏ច្រើននេះ ពួកគេត្រូវបានឃ្លាតចេញពីគ្រួសាររបស់ពួកគេនៅតាំងពីកុមារភាព ហើយត្រូវបានគេលក់ដោយមានកិច្ចសន្យាពលកម្មផង។

ពួកគេធ្វើការច្រើនម៉ោង ហើយធ្ងន់ធ្ងរថែមទៀត។ ជារឿយៗពួកគេត្រូវបានគេបំពានលើកម្លាំងកាយ កម្លាំងចិត្ត ស្មារតី និងផ្លូវភេទ។ ពួកគេអាចក្លាយជាជនពិការដោយសារការហូបចុក និងដេកតិចតួច ហើយធ្វើការងារ លំបាកទៀតផង។ ពួកគេគ្មានទស្សនទានអំពីកុមារ សង្គម និងការអប់រំឡើយ។ ពួកគេត្រូវបានតម្រង់ទិសសម្រាប់អនាគតដ៏ពិបាក ហើយកុមារភាពផ្ទាល់ខ្លួនរបស់ពួកគេនឹងចៀសមិនផុតពីការទទួលរងការធ្វើបាបទេ។

ប្រជាជន ពិសេសយុវជនក្មេងៗ ត្រូវការចង់ដឹងពីឥទ្ធិពលអាក្រក់នៃពលកម្មកុមារ ទោះបីវាមិនមានកើតឡើងក្នុងប្រទេសពួកគេក៏ដោយ។ ពួកគេគួរតែយល់ដឹងអំពីភាពហិនហោច និងបំផ្លិចបំផ្លាញស្មារតីពីកំណើតរបស់ពួកគេ ហើយពួកគេគួរតែខឹង ហើយចង់ធ្វើអ្វីមួយអំពីវា។ វាជាពេលសម្រាប់យុវជនក្មេងៗ ដែលត្រូវក្រោកឈរ និងត្រិះរិះ ពិចារណាហើយ។ ពួកគេត្រូវតែបង្ហាញកំហឹងចំពោះភាពអយុត្តិធម៌ទាំងនេះ ហើយទទួលបានព័ត៌មាននេះតាមរយៈសហគមន៍ដទៃទៀត។

ពួកគេត្រូវតែស្រែកគាំទ្រចំពោះការប្រឆាំងរបស់ពួកគេ ហើយនិងចូលរួមចំណែកធ្វើឱ្យមានភាពខុសគ្នា។ SCREAM មានន័យថា ការគាំទ្រសិទ្ធិកុមារតាមរយៈការអប់រំ សិល្បៈ និងប្រព័ន្ធសារព័ត៌មាន។ នេះគឺជាសារៈសំខាន់នៃគម្រោងពលកម្មដែលត្រូវបានដឹកនាំដោយសិស្សថ្នាក់ទី៤ ហើយ SCREAM គឺជាព័ត៌មានដែលយើងចង់ផ្តល់ទៅសហគមន៍ជាតិ និងអន្តរជាតិ។

នេះគឺជាហេតុផលដែលយើងចង់រៀបចំផ្ទាំងរូបភាពមួយដើម្បីគាំទ្រការងារគម្រោងនេះ។

ការរៀបចំផ្ទាំងរូបភាពដែលឈ្នះគេនឹងត្រូវបានផ្ញើទៅភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់ពិភពលោកនៃការងារអង្គការពលកម្មអន្តរជាតិ ។

យើងនឹងជំរុញគ្រប់បេក្ខជនឱ្យបញ្ចេញការស្រមើស្រមៃ ការច្នៃប្រឌិត និងការបង្កើតអ្វីដែលថ្មីឱ្យបានខ្លាំងក្លា។

ចូរគិតទៅដល់ពាក្យ SCREAM ហើយពាក្យនេះមានន័យ ដែលធ្វើឱ្យពិភពលោកចាប់អារម្មណ៏។ បន្ទាប់មក ចូរគិតទៅដល់ពលកម្មកុមារទៅដល់តម្រូវការ ភាពទុក្ខព្រួយ និងភាពឈឺចាប់របស់ពួកគេ ហើយស្វែងរកមធ្យោបាយមួយដើម្បីនាំយករូបភាពទាំងនេះទៅរៀបចំតាក់តែងបញ្ចូលគ្នាអោយល្អមើល។

**សំណាងល្អ !**

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡុង សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក វង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វ៉ិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


### សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឆីរ ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217

9 789995 088217